**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៥ . អនក្រ . បក

# អនុក្រឹត្យ

**ស្តីពី**

## ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ នៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**ស ម្រេ ច**

**មាត្រា១:-** ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ខេត្តពោធិសាត់ លើផ្ទៃដីទំហំ ១៩៥០ហិកតា (**មួយពាន់ ប្រាំបួនរយ ហាសិបហិកតា**) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រខេត្តពោធិសាត់ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **តឹន សា អភិវឌ្ឍន៍ ខូ អិលធីឌី** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកៅស៊ូ ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់មកជាមួយ ។

ឆ្នាំ ទី ១០ លេខ ៥២ សប្តាហ៍ទី ២ ថ្ងៃ ទី ១៥ ខែ កក្កដា ឆ្នាំ ២០១០ រាជកិច្ច ទំព័រ ៥៥៧៩

**មាត្រា២: -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

# ផែនទីទីតាំងដីវិនិយោគ អភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន គីង សា អភិវឌ្ឍន៍ ខូអិលធីឌី

## ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃសំកុស ភូមិសាស្ត្រខេត្តពោធិ៍សាត់ លើផ្ទៃដី ១៩៥០ ហិកតា




| ID | N | X | Y |
|---|---|---|---|
| 1 | A | 282660 | 1357409 |
| 2 | B | 281978 | 1357398 |
| 3 | C | 280493 | 1358429 |
| 4 | D | 280532 | 1359010 |
| 5 | E | 279982 | 1359902 |
| 6 | F | 279049 | 1359610 |
| 7 | G | 278127 | 1359432 |
| 8 | H | 277392 | 1359149 |
| 9 | I | 277845 | 1357784 |
| 10 | J | 273690 | 1357115 |
| 11 | K | 273867 | 1358951 |
| 12 | L | 276127 | 1358845 |
| 13 | M | 276868 | 1360835 |
| 14 | N | 278681 | 1361447 |
| 15 | O | 282695 | 1360858 |

មាត្រដ្ឋាន 1:33,000

សញ្ញាសម្គាល់

- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃ

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ........
ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ២០១០
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ផែនទី និងនិយាមការនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ........ សជណ
ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ២០១០

ប្រាក់-សុខុន